**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣១៨៤ កសក

រាជធានីភ្នំពេញ, ថ្ងៃទី..០៩.....ខែ..ឧសភា..ឆ្នាំ ២០១៤

**សូមជម្រាបមក**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល**

**កម្មវត្ថុ ៖** សំណើចាត់វិធានការត្រួតពិនិត្យលើការបង្ក្រាបបទល្មើសនៃការដឹកជញ្ជូន និងការចិញ្ចឹមត្រីឆ្តោ និងត្រីរ៉ស់ និងការត្រួតពិនិត្យផល ផលិតផលជលផលនាំចូលឲ្យមានប្រសិទ្ធភាពខ្ពស់។

**យោង ៖** -លិខិតលេខ៤០០៤ កសក.សជណ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-លិខិតលេខ១៦០៥ សជណ.កស ចុះថ្ងៃ០៧ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-លិខិតលេខ១០៧១ សជណ.សរ ចុះថ្ងៃ២៥ ខែសីហា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-លិខិតលេខ៧៣៨១ កសក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-លិខិតលេខ៩៣៧ កសក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផលថា កន្លងមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចេញសេចក្តីជូនដំណឹងស្តីពីការបញ្ឈប់សកម្មភាពចិញ្ចឹមត្រីឆ្តោ និងត្រីរ៉ស់ និងអនុញ្ញាតឲ្យរដ្ឋបាលជលផលធ្វើការចិញ្ចឹមពិសោធន៍ ស្រាវជ្រាវ តាមលិខិតដូចចុះយោងខាងលើ។ម្យ៉ាងទៀតក្រសួងក៏បានសម្រេចផ្អាកការអនុវត្តគោលការណ៍អនុញ្ញាត នាំចូល និងនាំឆ្លងកាត់ផលនេសាទប្រភេទត្រីរ៉ស់ ត្រីឆ្តោ ត្រីខ្មៀប និងត្រីផ្ទក់ ដែលពុំទាន់ធ្វើការកែច្នៃ កាត់ក្បាល ផងដែរ។ ប៉ុន្តែកន្លងមកក្រសួងសង្កេតឃើញថា រដ្ឋបាលជលផលពុំទាន់អនុវត្តការងារទាំងនេះឲ្យបានហ្មត់ចត់ប្រកបដោយប្រសិទ្ធភាពនៅឡើយ។ ដូចនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចឲ្យរដ្ឋបាលជលផលចាត់វិធានការឱ្យបានម៉ឺងម៉ាត់និងមានប្រសិទ្ធភាពខ្ពស់តាមចំណុចដូចខាងក្រោម ៖

១- ហាមដាច់ខាតរាល់ការនាំចូលនិងនាំឆ្លងកាត់ផលនេសាទប្រភេទត្រីរ៉ស់ ត្រីឆ្តោ ត្រីខ្មៀប និងត្រីផ្ទក់ ដែលពុំទាន់ធ្វើការកែច្នៃ កាត់ក្បាល និងត្រូវចាត់វិធានការយ៉ាងតឹងរ៉ឹងចំពោះជនណាដែលនាំចូល និងនាំឆ្លងកាត់ ផលនេសាទទាំងនេះពីក្រៅប្រទេស។

២- ត្រូវត្រួតពិនិត្យអនាម័យផលិតផលជលផលនាំចូលប្រកបដោយគុណភាព និងសុវត្ថិភាពដើម្បីធានាសុខុមាលភាពសាធារណៈ។

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

៣- ត្រូវបន្តការសិក្សាស្រាវជ្រាវបន្ថែមនូវការចិញ្ចឹមត្រីឆ្តោ និងត្រីរស់ដោយប្រើចំណីគ្រាប់ ចំណីផ្សំ ក្នុងវិទ្យាស្ថានវារីវប្បកម្ម និងតាមបណ្តាស្ថានីយវារីវប្បកម្មរដ្ឋនានានិងរាយការណ៍ពីលទ្ធផលជូនក្រសួង។ ទន្ទឹមនេះ រដ្ឋបាលជលផលត្រូវសិក្សាពីប្រព័ន្ធគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពមួយដែលអាចធានាការអនុវត្តច្បាប់សម្រាប់វារីវប្បករចិញ្ចឹមត្រីឆ្តោ ត្រីរស់នាពេលអនាគត។

៤- ត្រូវចាត់វិធានការយ៉ាងតឹងរ៉ឹងចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសចិញ្ចឹមត្រីឆ្តោ និងត្រីរស់ ដោយត្រូវពិន័យ ឬដាក់ទណ្ឌកម្មតាមច្បាប់ស្តីពីជលផលជាធរមាន។

អាស្រ័យហេតុនេះ សូមឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផលជ្រាប និងចាត់ចែងអនុវត្តតាមខ្លឹមសារខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់តាមការគួរ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ព្រះរាជាណាចក្រកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**ចម្លងជូន:**

- សាលារាជធានី ខេត្ត
  *"ដើម្បីជូនជ្រាប"*
- អគ្គាធិការដ្ឋាន
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- មន្ទីរកសិកម្ម រាជធានី ខេត្ត
  *"ដើម្បីជ្រាប"*
- ឯកសារ កាលប្បវត្តិ